ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០.៩៧......សហវ......

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការតម្រង់ទិសគម្រោងពន្លឿននវានុវត្តន៍ និងសហគ្រិនភាពបច្ចេកវិទ្យាស្អាតក្នុងធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីការបង្កើតមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការតម្រង់ទិសគម្រោងពន្លឿននវានុវត្តន៍ និងសហគ្រិនភាពបច្ចេកវិទ្យាស្អាតក្នុងធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា (Global Cleantech Innovation Programme: Accelerating cleantech innovation and entrepreneurship in start-ups and SMEs in Cambodia - GCIP Cambodia) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឯកឧត្តម **គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **ទិន ពន្លក** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាជនបង្គោលប្រតិបត្តិនៃមូលនិធិបរិស្ថានសកលប្រចាំនៅកម្ពុជា | អនុប្រធាន |

៣. ឯកឧត្តម **ហ៊ុល សៀងហេង** អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក

៤. ឯកឧត្តម **សេង សុភាព** ប្រធានបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សមាជិក

៥. តំណាង **UNIDO** ប្រចាំនៅរដ្ឋធានី វីយែន (Vienna) សាធារណរដ្ឋអូទ្រីស និងជាប្រធានគម្រោង(Project Manager) សមាជិក

៦. ឯកឧត្តម **ឈៀង វណ្ណមុនិណ្ណា** នាយកប្រតិបត្តិនៃសហគ្រិនខ្មែរ សមាជិក

៧. ឯកឧត្តម **តាំង ខួនលី** នាយកមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" លេខាធិការ។

**ប្រការ២..**

គណៈកម្មការតម្រង់ទិសគម្រោង (Project Steering Committee-PSC) ដែលបានបង្កើតឡើងតាមគោលការណ៍ស្ម័គ្រចិត្ត (Operates on a voluntary basis) មានតួនាទី និងភារកិច្ចដូចតទៅ៖

- តម្រង់ទិស ដឹកនាំ ត្រួតពិនិត្យ ផ្តល់អនុសាសន៍ និងជានាភាពជាម្ចាស់នៃគម្រោង (Institutional Ownership of the Project) ក្នុងការអនុវត្តគម្រោងឱ្យស្របទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត, ក្របខណ្ឌគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយមូលនិធិបរិស្ថានសកល និង វិធាននិងនីតិវិធីនៃការអនុវត្តគម្រោងរបស់អង្គការសហប្រជាជាតិ ដើម្បីអភិវឌ្ឍឧស្សាហកម្ម (UNIDO)
- សម្របសម្រួល និងគ្រប់គ្រងគម្រោងក្នុងកម្រិតម៉ាក្រូ
- ពិនិត្យ និងអនុម័តគម្រោងថវិកា ផែនការសកម្មភាព និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គម្រោង
- វាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំឆមាស ឬប្រចាំឆ្នាំ ព្រមទាំងលើកវិធានការ កែតម្រូវសម្រាប់ការអនុវត្តបន្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ និងលើកវិធានការកែតម្រូវសម្រាប់ការអនុវត្តនាឆ្នាំបន្ទាប់
- លើកសំណើ ឬផ្តល់យោបល់ក្នុងការកែសម្រួលគម្រោង, ឯកសារគម្រោង ឬវិសាលភាពគម្រោងតាមការចាំបាច់ ដោយពិភាក្សាជាមួយមូលនិធិបរិស្ថានសកលតាមរយៈ UNIDO។

**ប្រការ៣..**

គណៈកម្មការតម្រង់ទិសគម្រោងមានរបបប្រជុំសាមញ្ញ ២ (ពីរ) ដងក្នុងមួយឆ្នាំ។ ការប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកគណៈកម្មការចំនួន ២/៣ (ពីរភាគបី) នៃសមាជិកសរុប។ រាល់ការសម្រេចចិត្តត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នាផ្អែកលើសម្លេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មការដែលមានវត្តមានក្នុងពេលប្រជុំ។ ក្នុងពេលអនុម័តប្រសិនបើមានសម្លេងគាំទ្រស្មើគ្នា សម្លេងប្រធានអង្គប្រជុំមានឧត្តមានុភាព។ គណៈកម្មការតម្រង់ទិសគម្រោងអាចរៀបចំកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់។ សមាជិកគណៈកម្មការត្រូវទទួលបានការជូនដំណឹងជាមុនរយៈពេល១៥ថ្ងៃសម្រាប់កិច្ចប្រជុំសាមញ្ញ និងរយៈពេល៥ថ្ងៃសម្រាប់កិច្ចប្រជុំវិសាមញ្ញ។

**ប្រការ៤.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.**

សមាជិកដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ